## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២

## ជប៉ុនផ្តល់ ១០២,៨០៥ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់ កំពង់ផែតាជេសក្នុងខេត្តកំពង់ឆ្នាំង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូច សន្តិសុខមនុស្សជាតិ(*ជំនួយគូសាណូណេ*)រដ្ឋាភិបាលជប៉ុនបាន ផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន១០២,៨០៥ដុល្លា អាមេរិកដល់ក្រុមប្រឹក្សាឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងសម្រាប់គម្រោងសាងសង់ផែតាជេសក្នុងខេត្តកំពង់ឆ្នាំង។ កិច្ចសន្យាផ្តល់ជំនួយនេះត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាមូរ៉ា ហ៊ីរ៉ូស៊ី ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក សួស ស៊ីផៃ ប្រធានក្រុមប្រឹក្សាឃុំតាជេស នៅស្ថានទូតជប៉ុន។



តាមរយៈជំនួយនេះ សំណង់ផែបេតុងមួយ និងពោងបណ្តែតផែមួយនឹងត្រូវបាន សាងសង់ឡើងជំនួសឲ្យផែឈើចាស់ដោយក្រុមប្រឹក្សាឃុំតាជេសស្រុកកំពង់ ត្រឡាចខេត្តកំពង់ឆ្នាំង។ យើងសង្ឃឹមថា ផែបេតុងថ្មីនេះនឹងជួយសម្រួលដល់ ប្រជាជនប្រមាណ ២៨,៧២០នៅក្នុងឃុំ ៤ នៃតំបន់នោះក្នុងការធ្វើដំណើរឆ្លងកាត់ ទន្លេសាបដោយសុវត្ថិភាព។ ជាងនេះទៅទៀត ផែបេតុងថ្មីនេះនឹងជួយសម្រួលដល់ ការធ្វើដំណើរទៅសាលារៀនរបស់កុមារាកុមារីព្រមទាំងបង្កើនសកម្មភាពសេដ្ឋកិច្ច ដែលនឹងកែប្រែមុខមាត់ថ្មីសម្រាប់តំបន់ជុំវិញនោះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*)របស់ រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការ អភិវឌ្ឍន៍ និងស្តារនាប្រទេសឡើងវិញនៅកំរិតមូលដ្ឋាន។ជំនួយនេះមានគោលបំណងការពារ ជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រនិងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯង របស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់ អាជ្ញាធរ មូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៦៥នៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@.pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*